កាលខ្ញុំប្រលោមនាង



ខ្ញុំស្តាប់សាស័ព្ទពាក្យនោស្នូរ
ខ្ញុំប្រាប់ដោយគួរជាមេត្រី
បងមករកនាងណាពិសី
ដ្បិតនាងនាងស្រីស្តីសញ្ញា។

នោះឆ្លើយអ្នកអើយគួរពិភាល់
ប្អូនខ្វល់ឆ្ងល់ឆ្ងាយក្នុងចិន្តា
ខ្ញុំថាឆ្ងល់អ្វីកុំសង្កា
បានមើលសាស្ត្រាស្លូត្រឱ្យស្តាប់។

ឥឡូវធ្វើឆ្ងើងថាមិនស្គាល់
មានជាបន្ទាល់នៅដៃស្រាប់
ប្រាថ្នាមានឈ្នួតនិងជន្លាប់
ឱ្យបងសឹកឆាប់កុំយូរឡើយ។

នាងឮពាក្យខ្ញុំថាដូរខ្លោះ
ព្រឺព្រួចពុងពោះពុំមានស្បើយ
បើកទ្វារចេញមកថាលោកអើយ
ហ៊ានយកឈ្នួតហើយជាបន្ទាល់។

នរណាផ្តាំថានឹងឈ្នួតទៅ
ឱ្យអ្នកមកកូងនាំកង្វល់
ខ្ញុំថាបើបានតែដៃដល់
ប្រាប់មិនឱ្យឆ្ងល់សល់សេចក្តី។

នាងថានរណាបានប្តេជ្ញា
កោតតែវាចាហ៊ានស្រដី
ចូរអ្នកវិលទៅលំនៅខ្ទី
កុំនៅធ្វើអ្វីក្រែងពុំជា។

ខ្ញុំថានរណាគេនឹងឆោត
វិលទៅវិញសោកឱ្យឃ្លាតឃ្លា
នៅទាល់តែបានកែវពុំខា
មូលមួយផងគ្នាមិនបែកបង់។

នាងថាខ្លួនប្អូនប្រៀបដូចផ្កា
ឯអ្នកឧបមាដូចកន្លង់
ហើររកឃើញផ្កាចូលត្រឹបត្រង់
រួចមិនបន្ទង់ត្រេចលីលា។

ខ្ញុំថាខ្លួនបងដូចរាជសីហ៍
ខ្លួននាងនាងស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា
មិនឱ្យឃ្លាតឃ្លាគុហាឡើយ។

នាងថាខ្លួនប្អូនដូចកំពង់
ខ្លួនអ្នកឆោមយង់ដូចទូកហើយ
ចូលចតអាស្រ័យអ្នកថ្លៃអើយ
ចេញទៅកន្តើយមិននឹកនា។

ខ្ញុំថាឱ្យបងដូចត្រីធំ
ខ្លួននាងក្រមុំដូចគង្គា
ត្រីបានទឹកជ្រៅហែលរេរា
កុំកែវពុំខាគិតសង្ស័យ។

នាងថាខ្លួនប្អូនដូចព្រឹក្សា
អ្នកដូចសារិកាធំសព្វថ្ងៃ
ចតជាទ្រនំធំអាស្រ័យ
ហើយហើរច្រៀងច្រៃទៅទីទៃ។

ខ្ញុំថាខ្លួនបងប្រៀបដូចខ្លា
ខ្លួនកែវកន្និដ្ឋាប្រៀបដូចព្រៃ
ធម្មតាសត្វខ្លាមិនវិលវៃ
ចៀសចេញចោលព្រៃណា៎ថ្លៃបង។

នាងថាប្អូនដូចឈើបន្លង
ខ្លួនអ្នកប្រុសឈ្នួងដូចឃ្មុំផង
មកទំផ្ញើសាំហើរជាម្តង
ឈើសោកសៅហ្មងអសារនៅ។

ខ្ញុំថាខ្លួនបងដូចដំរី
ខ្លួនប្អូនស្រស់ស្រីដូចអំពៅ
ដំរីបានផ្តែមមិនដែលទៅ
ឆ្ងាយពីអំពៅណា៎អូនណា៎។

នាងថាឱសឱ្យអ្នកថ្លៃអើយ
នរណាដោយហើយកុំសង្កា
ពាក្យប្រុសភូតព្រៀងអាងប្រាថ្នា
កុំណា៎ខ្ញុំថាកុំសង្ស័យ។

នាងមានវោហារប្រាថ្នាដោះ
ខ្ញុំគ្មានខ្លាចសោះចូលចាប់ដៃ
ជើបថៃថានែ៎អ្នកមាសថ្លៃ
នៅតែសង្ស័យមិនជឿចិត្ត។

នាងខឹងក្រញឹងឥតកោតក្រែង
ចាប់ដៃកំហែងគ្មានអាណិត
ថានឹកគួរភ្ញាញ់ម្ញេញមិនស្បិត
កោតចិត្តហៅហ៊ានរុករានព្រៃ។

ខ្ញុំឱ្យបបីបមថ្នមប្រលែង
ចិត្តគ្មានគិតក្រែងមិនខបថៃ
ហើយថាបើខុសសូមឱ្យថ្លៃ
ស្រលាញ់យូរថ្ងៃឥតឧបមា។

នាងស្រួលទទួលព្រមចូលជិត
ខ្ញុំសោកស្នេហ៍ស្និទ្ធថើបភ័ក្ត្រា
ទាំងពីរហ៊ានស្បថប្រាកដថា
ខ្ជាក់ស្លាប្លូរគ្នារួចនាងឆ្លើយ។

អ្នកថ្លៃប្អូនអើយក្រែងអ្នកបង
បានរួមស្នេហ៍ស្នងនៅកៀកកើយ
ចេញចាកចោលប្អូនទេដឹងអើយ
អ្នកអើយអាសូរចិត្តប្អូនរ៉ា។

ខ្ញុំថើបលួងលោមថ្លៃនួនល្អង
ថាឱ្យមាសបងដួងជីវ៉ា
បងមិនដោះដៃចោលកន្និដ្ឋា
បងផ្ញើអាត្មាអស់ជន្មជីព។

ដ្បិតប្អូនមានគុណប្រៀបដូចភ្នំ
សុមេរុធារធំសង្កត់ទ្វីប
ខ្លួនបងធៀបដូចកល់សុត្រីព
ជន្មជីពផ្ញើលើព្រះរាមា។

នាងថាខ្លួនប្អូនដូចតារា
ប្រុសថ្លៃស្នេហាដូចចន្ទ្រា
តារារះរាយលើមេឃា
អមអង្គចន្ទ្រាមិនមានឃ្លាត។

បងអើយយប់ហើយចូលសយនា
ស្និទ្ធស្នាលស្នេហាលុះអាធ្រាត
ខ្ញុំសុំថ្នបនាងគ្រប់សព្វជាតិ
ពុំឃ្លាតពុំឃ្លៀងវៀងគេទៅ។

ព្រះបទុមត្ថេរ សោម